**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា
# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ថ្លែងក្នុងឱកាសបើក
# កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៤
# នៅទីស្ដីការគណៈរដ្ឋមន្ត្រី
# ថ្ងៃអង្គារ ៥ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
# ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤

- សូមគោរពអង្គពិធីទាំងមូល
- ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង លេខាធិការដ្ឋានរាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា
- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!

’ ថ្ងៃនេះខ្ញុំពិតជាមានកិត្តិយស និងក្ដីសោមនស្សក្រៃលែងដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៤**”។ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្ដែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គ លើកទីមួយសម្រាប់ឆ្នាំ២០២៤ នាពេលនេះ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងនូវការកោតសរសើរដ៏ស្មោះ ជូនចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការខិតខំប្រឹងប្រែង និងកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីជំរុញ និងចូលរួមអនុវត្ត "សេចក្ដីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជារហូតបានទទួលលទ្ធផលជាផ្លែផ្កាគួរជាទីពេញចិត្ត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា** !

ក្នុងដំណើរឆ្ពោះទៅបញ្ចប់អេដស៍ដែលជាគ្រោះគម្រាមកំហែងដល់សុខភាពសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ជាពិសេសនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ កន្លងទៅ កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុម័តជាឯកច្ឆន្ទដាក់ចេញនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ សំដៅកសាងកម្ពុជាមួយគ្មានអេដស៍។

គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ បានបញ្ជាក់នូវការប្តេជ្ញាចិត្ត ផ្នែកនយោបាយយ៉ាងមុតមាំបន្ថែមទៀតរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលបន្តបេសកកម្មដ៏ថ្លៃថ្លាពីរាជរដ្ឋាភិបាលនីតិកាលមុនៗ ក្រោមការដឹកនាំដ៏ឆ្នើមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងការបន្តអភិវឌ្ឍន៍មូលធនមនុស្ស និងការលើកកម្ពស់សុខភាព និងសុខមាលភាពប្រជាជន សមស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។

គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ បានត្រូវរៀបចំឡើងជាឧបករណ៍ដ៏មុតស្រួចក្នុងការជំរុញការចូលរួមការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ជាលក្ខណៈពហុវិស័យទាំងនៅថ្នាក់ជាតិ និងទាំងនៅថ្នាក់ក្រោមជាតិដោយឈរលើសសរស្តម្ភទាំងបីគឺ៖ ១) ភាពជាអ្នកដឹកនាំ ឬភាពជាម្ចាស់ ២)ភាពជាដៃគូ និង៣) ការវិនិយោគ រួមជាមួយគោលការណ៍បី មួយគឺ៖ យុទ្ធសាស្ត្រ ឬក្របខ័ណ្ឌផែនការសកម្មភាពតែមួយ, ស្ថាប័នសម្របសម្រួលតែមួយ និងប្រព័ន្ធតាមដាន និងវាយតម្លៃតែមួយ។

លើសពីនេះ គោលនយោបាយជាតិក៏បានចង្អុលទិស ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយនិងពហុវិស័យលុបបំបាត់ជំងឺអេដស៍ ដើម្បីធានានូវការឆ្លើយតបមួយឱ្យបានសមស្របទៅនឹងសេចក្តីត្រូវការជាអាទិភាពក្នុងចំណោមក្រុមគោលដៅ រួមជាមួយនឹងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធផលនិងប្រសិទ្ធភាពឈានទៅសម្រេចបាននូវគោលដៅតាមកាលកំណត់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**!

ខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមគម្រោងផែនការសកម្មភាពឆ្នាំ២០២៤ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទីមួយ ធ្វើឡើងដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល ប្រសិទ្ធភាពឬបញ្ហាប្រឈមក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់រយៈពេល៦ខែដើមឆ្នាំ២០២៤ ។

តាមរបៀបវារៈ កិច្ចប្រជុំយើងនឹងមានបទបង្ហាញចំនួនពីរ រួមមាន ៖

ទី១. បទបទបង្ហាញ**សេចក្ដីព្រាងស្ដីពីវឌ្ឍនភាពនៃការអនុវត្តសេចក្ដីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២៣** បង្ហាញជូនដោយ**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ទី២.បទបង្ហាញ**ស្ដី**ពីគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ បង្ហាញជូនដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

បន្ទាប់មកយើងនឹងមានការពិភាក្សារួមគ្នា និងដាក់ចេញនូវសេចក្ដីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទីមួយ ឆ្នាំ២០២៤ ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្ដូរយោបល់ និងបទពិសោធន៍ការងារពីបណ្ដាសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំត្រឹមប៉ុណ្ណេះ។

ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៤**" ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!